# សុន្ទរកថា

## ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្រ្តីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និង សិប្បកម្ម ឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារឆ្នាំ២០២០

ថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០

- *គណៈអធិបតី!*
- *ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម!*
- *ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី តំណាងក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល សមាគម អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកា អង្គសន្និបាត ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំពិតជាមានមោទនភាព និងសោមនស្សរីករាយ ដោយទទួលបានកិត្តិយសដ៏ខ្ពង់ខ្ពស់ ធ្វើជាតំណាង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មកចូលរួមជា **អធិបតី** ក្នុងពិធីបើក **សន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារឆ្នាំ២០២០** ក្រោយរយៈពេលជាងមួយឆ្នាំនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។ នេះក៏ជាឱកាសល្អមួយសម្រាប់រូបខ្ញុំ ដែលបានមកទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្មជាលើកទី២ ក្នុងរយៈពេល៣ឆ្នាំកន្លងទៅ។ អ្វីដែលខ្ញុំបានឃើញមុនគេ ហើយប្លែកពីពេលមុន គឺការដ្ឋានសំណង់អគារទីស្តីការថ្មីរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម កម្ពស់១៨ជាន់ ដែលកំពុងដំណើរការសាងសង់ នៅផ្នែកខាងមុខ ហើយដែលអាចចាត់ទុកថា ជាសមិទ្ធផលថ្មីមួយទៀតរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅរាជធានីភ្នំពេញ និងជាការរួមចំណែកដល់ការលើកស្ទួយមុខមាត់

ព្រមទាំងកែលម្អសោភ័ណភាពរាជធានីភ្នំពេញ ដែលជាបេះដូងរបស់ប្រទេសជាតិ។ ការកសាងសមិទ្ធផលថ្មីនេះទៀតសោត ក៏ស្របពេលដែលរាជរដ្ឋាភិបាល ទើបតែបានអនុម័តនូវសេចក្តីព្រាងច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើមូលដ្ឋាននៃក្រសួងឧស្សាហកម្ម និងសិប្បកម្មបច្ចុប្បន្ន, នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០។ ខ្ញុំជឿជាក់ថា សំណង់អគារទីស្តីការថ្មីនេះ នឹងឆ្លើយតបបានទៅនឹងការផ្លាស់ប្តូរ រៀបចំរចនាសម្ព័ន្ធរបស់ក្រសួងថ្មីនៅពេលខាងមុខ និងបំពេញបាននូវសេចក្តីត្រូវការរបស់មន្ត្រីរាជការក្រោមឱវាទ អំពីបញ្ហាកន្លែងធ្វើការប្រចាំថ្ងៃ ក៏ដូចជាបង្កភាពងាយស្រួលជាងមុន ក្នុងការបម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋ ឬធុរជន។

ក្រោមម្លប់សន្តិភាព ដែលបានកើតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងមាគ៌ាដ៏ត្រឹមត្រូវ ប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា,** ប្រទេសជាតិរបស់យើងក្នុងរយៈពេល ២០ចុងក្រោយនេះ សម្រេចបាននូវសមិទ្ធផលជាច្រើនឥតគណនា ជាមួយនឹងការថែរក្សាបាននូវឯកភាពជាតិ, ស្ថិរភាពនយោបាយ, ស្ថិរភាពសង្គម ព្រមទាំងការពារបាននូវបូរណភាពទឹកដី និងអធិបតេយ្យជាតិយ៉ាងរឹងមាំ។

ក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំសូមពាំនាំនូវការផ្តាំផ្ញើ សាកសួរសុខទុក្ខដោយក្តីនឹករលឹក និងថ្លែងនូវការអរគុណពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជូនចំពោះថ្នាក់ដឹកនាំ, មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងគ្រប់ផ្នែកពាក់ព័ន្ធដទៃទៀត ដែលបានចូលរួមបំពេញភារកិច្ច កាតព្វកិច្ចតាមមុខសញ្ញារៀងៗខ្លួន ធ្វើឱ្យរាជរដ្ឋាភិបាលកាន់តែពង្រឹងបានឧត្តមភាព និងសម្រេចជោគជ័យ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងបន្តសម្រេចបាននូវសូចនាករសំខាន់ៗ នៃយុទ្ធសាស្តចតុកោណដំណាក់កាលទី៤ ក្នុងនីតិកាលទី៦នេះ។

- ***ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា!***

នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ បានគូសបញ្ជាក់ច្បាស់ពីចក្ខុវិស័យ និងគោលដៅជាយុទ្ធសាស្ត្រជាក់លាក់របស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យគ្រប់ផ្នែក គ្រប់ថ្នាក់ យកចិត្តទុកដាក់លើបញ្ហាគន្លឹះទាំងនេះដោយមធ្យ័ត មានដូចជា៖ (១)ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ (២)បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ជូនប្រជាជនកម្ពុជា ពិសេស សម្រាប់ស្រទាប់យុវជន (៣)សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% និង(៤)បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យបានកាត់តែប្រសើរឡើង ក៏ដូចជា លើកកម្ពស់បរិយាកាសធុរកិច្ច និងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាមេបញ្ជាការដ៏ប៉ិនប្រសប់ ប្រកបដោយបញ្ញាញាណ ខាងនយោបាយ ការទូត សេដ្ឋកិច្ច និងការពារជាតិ បានដឹកនាំប្រទេសជាតិរបស់យើង សម្រេចបាននូវការរីកចម្រើនគួរជាទីមោទនៈ និងភាព

កក់ក្ដៅ។ កិត្យានុភាពជាតិ និងមុខមាត់របស់ប្រទេសកម្ពុជាកាន់តែត្រូវបានលើកកម្ពស់នៅលើឆាកអន្តរជាតិ។ បណ្ដាប្រទេសក្នុងតំបន់ និងពិភពលោកបានទទួលស្គាល់ និងវាយតម្លៃខ្ពស់ចំពោះស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា។

នៅក្នុងនីតិកាលទី៦នេះ កំណែទម្រង់រដ្ឋសុីជម្រៅ និងទូលំទូលាយ ត្រូវបានជំរុញអនុវត្តដោយឆន្ទៈមុតស្រួច និងមានប្រសិទ្ធភាព។ កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៩ ត្រូវបានប៉ាន់ប្រមាណថា នឹងសម្រេចបាន៧,១% លើសពីការព្យាករណ៍ពីដំបូង ក្នុងបរិការណ៍អតិផរណាទាប ជាមួយនឹងអត្រាប្តូរប្រាក់មានស្ថិរភាពល្អ។ កំណើនសេដ្ឋកិច្ចនេះ ត្រូវបានគាំទ្រដោយកំណើនដ៏ល្អក្នុងវិស័យសេវាកម្ម និងកំណើនខ្ពស់នៃវិស័យឧស្សាហកម្ម ទោះបីមានការថមថយបន្តិច ខណៈដែលវិស័យកសិកម្មនៅមានកំណើនទាប។ ពិតណាស់ថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមការដឹកនាំរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវការទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥។ ជាក់ស្តែង តាមរយៈសុន្ទរកថាស្វាគមន៍របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ**, អង្គសន្និបាតពិតជាបានយល់ជ្រាបច្បាស់ហើយ អំពីលទ្ធផល និងស្នាដៃការងារសំខាន់ៗដែលក្រសួងឧស្សាហកម្ម និងសិប្បកម្មសម្រេចបានក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ដូចបានបង្ហាញជូននូវតួលេខមួយចំនួនជាទឡ្ហីករណ៍។ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមឯកភាព និងវាយតម្លៃខ្ពស់ ចំពោះការខិតខំបំពេញភារកិច្ច និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មទាំងអស់ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗទៀត ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្នុងនីតិកាលទី៥ កន្លងទៅ ក៏ដូចជានៅដើមនីតិកាលទី៦នេះ។ កិច្ចខិតខំទាំងអស់នេះ បាននាំមកនូវសមិទ្ធផលនានាគួរជាទីមោទនៈ និងបានធ្វើឱ្យវិស័យឧស្សាហកម្មកម្ពុជា មានការអភិវឌ្ឍរីកចម្រើនពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ ជាពិសេស ក្នុងដំណាក់កាលដែលកម្ពុជាកំពុងតែផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម។ យើងអាចនិយាយបានថា វិស័យឧស្សាហកម្មគឺជាកម្លាំងចលករមួយដែលមិនអាចខ្វះបាន ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយបរិយាប័ន្ន និងភាពធន់។ ការអភិវឌ្ឍវិស័យនេះ គឺជាឧបករណ៍នយោបាយប្រកបដោយប្រសិទ្ធភាព សម្រាប់ការតភ្ជាប់រវាងវិស័យសេដ្ឋកិច្ចសំខាន់ៗ ដែលជា *«ម្ចាស់»* ជំរុញកំណើន និងបង្កើតការងារបន្ថែមក្នុងវិស័យកសិកម្ម, ទេសចរណ៍, និងសេវាកម្ម, ព្រមទាំងរួមចំណែករំដោះអតិរេកពលកម្មពីវិស័យកសិកម្ម ដែលធ្វើឱ្យផលិតភាពសរុបកើនឡើង និងមានចំណូលខ្ពស់ជាងមុន។ ម្យ៉ាងទៀត វិស័យឧស្សាហកម្ម ក៏រួមចំណែកដ៏សំខាន់ក្នុងការបង្កើតការងារ ការបង្កើនប្រាក់ចំណូល និងការលើកកម្ពស់ផលិតភាព, តាមរយៈការវិនិយោគ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ, រួមទាំងការបង្កើតការងារក្នុងវិស័យគាំទ្រដទៃទៀត នៅក្នុងគ្រប់ខ្សែចង្វាក់តម្លៃ ចាប់តាំងពី

ការផលិត និងការផ្គត់ផ្គង់វត្ថុធាតុដើម, សេវាកម្មដឹកជញ្ជូន និងឡូជីស្ទីក, វិស័យហិរញ្ញវត្ថុ និងបណ្តុះបណ្តាលជំនាញជាដើម។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជាលើកទឹកចិត្តដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបន្តកិច្ចសហការគ្នាជាកម្លាំងរួម ជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ខិតខំជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង, ការលើកកម្ពស់ផលិតភាព និងការលើកស្ទួយផលិតកម្មក្នុងស្រុក។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានតាំងចិត្តយ៉ាងមុតមាំ ក្នុងការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់កម្មករ និយោជិត និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អតីតមន្ត្រីរាជការ និងយោធិនតាមរយៈការគិតគូរដល់ការដំឡើងប្រាក់បៀវត្ស ប្រាក់សោធននិវត្តន៍ និងប្រាក់ឈ្នួលអប្បបរមា។ ជាក់ស្តែងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ត្រូវបានដំឡើងជារៀងរាល់ឆ្នាំ ដែលកាលពីឆ្នាំ២០១៨ កើនដល់ ១៧០ដុល្លារ និងកើនបន្ថែមដល់ ១៨២ដុល្លារ នៅឆ្នាំ២០១៩ ហើយបន្តកើនឡើងដល់ ១៩០ដុល្លារ ចាប់ពីខែមករា ឆ្នាំ២០២០នេះតទៅ ដោយមិនទាន់គិតដល់ការទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗទៀត ពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាលដែលត្រូវបានដាក់ចេញ ជាអាទិ៍ របបធានារ៉ាប់រងហានិភ័យការងារ និងរបបធានារ៉ាប់រងសុខភាព ការថែទាំសុខភាពជាដើម។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវរបបធានារ៉ាប់រងផ្នែកសោធននៅឆ្នាំ២០១៩ កន្លងទៅផងដែរ។ ដោយឡែក ប្រាក់បៀវត្សរបស់មន្ត្រីរាជការ ក៏ត្រូវបានដំឡើងជាបន្តបន្ទាប់ តាមរយៈការដាក់ចេញនូវអនុក្រឹត្យកាលពីដើមខែធ្នូ កន្លងទៅ ក្នុងការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ (ដោយបានកែប្រែតម្លៃឯកតាពី ២៣៤០រៀល ទៅ ២៥០០រៀលក្នុងមួយសន្ទស្សន៍ និងត្រៀមពិនិត្យកែសម្រួលប្រាក់បំណាច់មុខងារនៅក្នុងអំឡុងខែមេសា ឆ្នាំនេះផងដែរ។ គោលនយោបាយគាំទ្រនេះ បាន និងកំពុងជះឥទ្ធិពលដល់កំណើន និងប្រសិទ្ធភាពការងារលើគ្រប់វិស័យ។

- ***ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!***

ជាមួយនឹងសំណុំឯកសាររបស់អង្គសន្និបាត ដែលត្រូវបានចែកជូនដល់អ្នកចូលរួមរួចហើយ និងការថ្លែងដោយសង្ខេបរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** នៅពេលមុននេះ, ខ្ញុំយល់ថា អ្នកចូលរួមទាំងអស់នឹងបានស្វែងយល់ បានឃើញអំពីលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលសម្រេចបាននារយៈពេលកន្លងទៅ និងទិសដៅដែលក្រសួងបានដាក់ចុះ សម្រាប់អនុវត្តបន្តដោយពុំមានភាពចាំបាច់ឱ្យខ្ញុំរំលឹកឡើងវិញ អំពីសូចនាករជាតួលេខមួយចំនួនបន្ថែមទៀតនោះទេ។ ប៉ុន្តែនៅទីនេះ អ្វីដែលខ្ញុំបានគិត និងចង់ទាញអារម្មណ៍អង្គសន្និបាត គឺថា ក្រសួងឧស្សាហកម្ម និងសិប្បកម្មកំពុងដើរដល់ដំណាក់កាលថ្មីមួយ ដែលត្រូវធ្វើការកែទម្រង់ស៊ីជម្រៅកាន់តែជ្រាលជ្រៅជាងពេលមុនៗ ជាពិសេស ការកែទម្រង់ការគ្រប់គ្រង ដឹកនាំស្ថាប័ន ក្នុងខណៈដែលក្រសួងមួយនេះ ត្រូវបានរាជរដ្ឋាភិបាលសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ ស្តីពីការបង្កើត **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ទៅស្ថាប័នរដ្ឋសភាជាតិ ក្រោយពីត្រូវបានអនុម័តក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីពេលថ្មីៗនេះ

ដើម្បីស្នើសុំការគាំទ្រ និងអនុម័តពីរដ្ឋសភាជាតិ និងពីស្ថាប័នព្រឹទ្ធសភា។ បន្ថែមលើនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏នៅមានកិច្ចការជាច្រើន ដែលត្រូវដោះស្រាយបញ្ហាប្រឈមស្មុគស្មាញនានា ទាមទារឱ្យមានការខិតខំប្រឹងប្រែងទ្វេឡើង ដូចមតិលើកឡើងរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី** ដែលបានធ្វើសេចក្តីថ្លែងហេតុ នៅចំពោះមុខអង្គប្រជុំគណៈរដ្ឋមន្ត្រី កាលពីថ្ងៃសុក្រ ទី៧ ខែកុម្ភៈ មុននេះ។ ក្នុងស្ថានភាពនេះ ខ្ញុំស្នើដល់ថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលអនាគតមិនយូរប៉ុន្មាន នឹងក្លាយទៅជា *ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)* សូមយកអស់ស្មារតី បន្តប្រពៃណីសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងសហការស្អិតល្អួតជាមួយដៃគូជាតិ អន្តរជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ខិតខំប្រឹងប្រែងជម្នះការលំបាកទាំងឡាយ ដើម្បីរិះរកវិធានការដោះស្រាយប្រកបដោយភាពប្រទាក់ក្រឡាគ្នា ជានាប្រសិទ្ធភាពខ្ពស់ ក្នុងការដោះស្រាយបញ្ហាលំបាកស្មុគស្មាញចំពោះមុខ និងការណ៍ដែលអាចនឹងកើតមានឡើងនៅពេលខាងមុខ តម្រូវឱ្យយើងវាយតម្លៃទុកជាមុននូវសភាពការណ៍នេះ។

ក្នុងន័យនេះ ខ្ញុំសូមយកឱកាសនៃការប្រារព្ធពិធីបើកសន្និបាតនៅព្រឹកនេះ គូសបញ្ជាក់ និងដាក់ចេញជាអនុសាសន៍មួយចំនួន សម្រាប់អង្គសន្និបាតធ្វើជាមូលដ្ឋានគិតគូរពិចារណា និងពិភាក្សា រិះរកដំណោះស្រាយ ព្រមទាំងដាក់ចេញជាវិធានការអនុវត្តឱ្យបានដាក់លាក់ សម្រាប់រយៈពេលបន្ត ដូចតទៅ៖

## ក- ការកែទម្រង់ការគ្រប់គ្រង ដឹកនាំក្រសួង

### ១- *អំពីដំណើរការរៀបចំក្រសួងថ្មី ជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖*

- គឺត្រូវបន្តអនុវត្តនីតិវិធី នៃការស្នើសុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងថ្មីនេះ ទៅស្ថាប័ននីតិបញ្ញត្តិ តាមពេលវេលាដ៏ឆាប់ដែលអាចធ្វើទៅបាន។ ព្រមគ្នានេះដែរ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបន្តធ្វើការជាមួយក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ដើម្បីរៀបចំ កែសម្រួលចំណុចមួយចំនួន នៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទៅតាមស្មារតីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងមតិដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, ដែលបញ្ហានេះ ខ្ញុំនឹងជួយសម្របសម្រួលដឹកនាំដោយផ្ទាល់។
- ចំពោះការរៀបចំមុខតំណែងមន្ត្រីក្នុងជួរថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំនៅតាមអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ជាកិច្ចការដែលត្រូវធ្វើជាចាំបាច់ និងមានលក្ខណៈបន្ទាន់ផងដែរ ក្រោយពីច្បាប់ស្តីពីការបង្កើតក្រសួងថ្មីនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រម។ ការរៀបចំមន្ត្រីក្នុងមុខតំណែងមួយចំនួន ទាំងសម្រាប់អង្គភាពថ្នាក់អគ្គនាយកដ្ឋានថ្មីចំនួនពីរ ទាំងអង្គភាពក្រោមឱវាទក្រសួងបច្ចុប្បន្ន ក៏ត្រូវឆ្លងកាត់នីតិវិធីត្រឹមត្រូវ ច្បាស់លាស់ ដែលប្រហែលជាមិនសាមញ្ញ និងប្រើពេលខ្លីឆាប់រហ័សនោះទេ។ ប្រការនេះ ទាមទារឱ្យមានការគិតគូរ គាក់តែងលិខិតស្នាមត្រៀមរៀបចំពីឥឡូវនេះទៅ។
- ត្រូវធ្វើការគិតគូរទុកជាមុន អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលកំពុងស្ថិតនៅជាធរមាន ហើយដែលមានភាពចាំបាច់ត្រូវធ្វើវិសោធនកម្ម ដើម្បីឱ្យស្របទៅនឹងច្បាប់ស្តីពី

ការបង្កើតក្រសួងថ្មី និងតួនាទី មុខងារ បេសកកម្មរបស់ក្រសួងថ្មី គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

- ខ្ញុំសូមគាំទ្រទស្សនៈរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ដែលបានបញ្ជាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីជ្រាបថា ក្រសួងថ្មីនេះ នឹងមិនធ្វើអ្វីប៉ះពាល់ដល់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័នជំនាញនានាដែលកំពុងអនុវត្តនោះទេ **ហើយយកស្មារតីសហការជាធំ** ដើម្បីរួមគ្នាជំរុញ និងអភិវឌ្ឍន៍វិស័យដែលទើបបានបង្កើតឡើងគឺ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ស្របតាមដំណាក់កាលរីកចម្រើនរបស់សកលលោក។

*២- ការផ្ទេរសមាហរណកម្មរចនាសម្ព័ន្ធការិយាល័យជំនាញ របស់ក្រសួង ស្ថាប័ន ទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៖*

- នេះក៏ជាកិច្ចការដែលក្រសួង ត្រូវចាត់ទុកថា ជាការងារអាទិភាពមួយ និងចាត់ចែងអនុវត្តឱ្យបានទាន់ពេលវេលាកំណត់ ទៅតាមការចង្អុលណែនាំរបស់ គណៈកម្មាធិការជាតិអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។ សន្និបាតនាពេលនេះ ក៏មានវត្តមានប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត នៅទីនេះស្រាប់, ខ្ញុំយល់ថា លោកប្រធានមន្ទីរអាចនឹងផ្តល់មតិបន្ថែមក្នុងកម្មវិធីពិភាក្សារបស់អង្គសន្និបាត ដើម្បីរៀបចំជាវិធានការអនុវត្តនាពេលចំពោះមុខ លើកិច្ចការខាងលើ។
- ផ្សារភ្ជាប់ទៅនឹងការផ្ទេរសមាហរណកម្មរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ក៏គួរបានពិនិត្យមើលឡើងវិញលក្ខណៈសម្បត្តិ និងប្រភេទសេវា ឬមុខងារ ដែលគួរត្រូវបានធ្វើប្រតិភូកម្មបន្ថែមជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេស រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។ ជាមួយគ្នានេះ ត្រូវធ្វើការវាយតម្លៃលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមាន នៃការអនុវត្តមុខងារដែលត្រូវបានធ្វើប្រតិភូកម្មឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មកន្លងទៅ។ ផ្អែកលើមូលដ្ឋាននៃការវាយតម្លៃនេះ ក្រសួងអាចនឹងពិចារណាធ្វើការកែសម្រួលបែបបទ នីតិវិធី ប្រព័ន្ធការងារបន្ថែមទៀត ដើម្បីឱ្យ សេវារដ្ឋបាលរបស់យើង កាន់តែត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ និងធុរជន ប្រកបដោយភាពងាយស្រួល មានទំនុកចិត្ត និងតម្លាភាព។

*៣- ការចូលរួមអនុវត្តវិធានការកែទម្រង់មុតស្រួច ជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ (កាលពី ខែមីនា ឆ្នាំមុន) និងវិធានការបន្ថែមនានា ក្រោមក្របខណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ដែលបានឯកភាព និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៩, ការពិនិត្យលទ្ធភាពនៃការធ្វើឱ្យប្រសើរឡើង នូវភាពងាយស្រួលក្នុងការធ្វើធុរកិច្ចនៅកម្ពុជា (Ease of Doing Business in Camodia).*

- ខ្ញុំបានដឹងថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង ចូលរួមជាតំណាងនៅក្នុងក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជនដែលមានចំនួន ១៣ក្រុមការងារ ដូចមានចែងក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលរួចហើយ

ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។ អ្វីដែលជាកិច្ចការសំខាន់ត្រូវអនុវត្ត គឺគ្រប់ក្រុមការងារទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តចំណុចជាយុទ្ធសាស្ត្រគន្លឹះ និងមានចរិតជាវិធានការកែទម្រង់មុតស្រួច ដែលត្រូវបានដាក់ចេញដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨។ ចំពោះបញ្ហានេះ ខ្ញុំស្នើដល់ក្រសួង ស្ថាប័ន និងមន្ត្រីដែលមានការពាក់ព័ន្ធទាំងអស់ ត្រូវខិតខំស្វែងរកដំណោះស្រាយលើចំណុចដែលនៅសេសសល់ និងត្រៀមបទអន្តរាគមន៍ លើកយោបល់ជូនរាជរដ្ឋាភិបាល នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ដែលគ្រោងធ្វើឡើងនៅដើមខែមេសា ខាងមុខ។

- យើងត្រូវរួមសហការគ្នា ដោះស្រាយបញ្ហាប្រឈម ឬកង្វល់របស់វិនិយោគិន និងអ្នកប្រកបរបរអាជីវកម្ម សេវាកម្មនានាឱ្យបានជាអតិបរមា និងកាន់តែខិតខំជួយសម្រួល បង្កលក្ខណៈដល់វិស័យឯកជន ក្នុងការកាត់បន្ថយការចំណាយក្នុងផលិតកម្ម, ការដឹកជញ្ជូន, ការនាំចេញ និងសេវារដ្ឋបាលផ្សេងៗ ក្នុងពេលដែលប្រទេសរបស់យើងកំពុងប្រឈមនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅក្នុងទីផ្សារពិភពលោក ពិសេសទីផ្សារសហគមន៍អឺរ៉ុប។

## ខ- ការអភិវឌ្ឍវិស័យឧស្សាហកម្ម

១- គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ២០១៥-២០២៥ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ មានភាពប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។ ក្នុងក្របខណ្ឌនៃគោលនយោបាយនេះ រាជរដ្ឋាភិបាល ដែលមានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ បានដាក់ចេញជាបន្តបន្ទាប់នូវវិធានការចាត់តាំងអនុវត្ត តាមដំណាក់កាលនីមួយៗ និងកំណត់អំពីសូចនាករដែលត្រូវឆ្លើយតប, ក្នុងនោះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏ដើរតួនាទីជាស្ថាប័ននាំមុខលើសកម្មភាពការងារមួយចំនួន ហើយលើផ្នែកមួយចំនួនផ្សេងទៀតដើរតួជាស្ថាប័នចូលរួមសម្របសម្រួល។ ក្នុងន័យនេះ ខ្ញុំស្នើក្រសួងឧស្សាហកម្ម និងសិប្បកម្ម បន្តផ្តោតការយកចិត្តទុកដាក់លើការបំពេញតួនាទីនេះ ដើម្បីឆ្លើយតបទៅនឹងសូចនាករកំណត់ ប្រកបដោយប្រសិទ្ធភាព ដោយរៀបចំជាផែនការការងារ, ការពិនិត្យតាមដានលើការអនុវត្ត និងវាយតម្លៃច្បាស់លាស់។

២- បន្តចូលរួមជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្ម ដោយខិតខំទាក់ទាញការវិនិយោគបន្ថែមទៀត និងការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មដល់ធុរជន និងវិនិយោគិន។ ជាមួយគ្នានេះ បន្តគាំទ្រ និងលើកទឹកចិត្តដល់ផ្នែកឧស្សាហកម្ម ឬកម្មន្តសាលថ្មីៗដែលផ្តល់តម្លៃបន្ថែមខ្ពស់ មានការច្នៃប្រឌិត និងភាពប្រកួតប្រជែងខ្ពស់ ដែលផ្តោតលើផលិតផលប្រើប្រាស់ និងសម្ភារបរិក្ខារផលិតកម្ម, គ្រឿងចក្រ, ការផ្គុំដំឡើងសម្ភារបរិក្ខារ, មេកានិច អេឡិចត្រូនិក, និងការកែច្នៃធនធានធម្មជាតិជាដើម ដែលមានចរិតជាការបើកច្រកចូលទីផ្សារក្នុង និងក្រៅប្រទេស។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរួមសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យ *«ប្រែក្លាយពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មអតិជំនាញត្រឹមឆ្នាំ២០២៥»*។

៣- ខ្ញុំសូមកោតសរសើរ ចំពោះការរីកចម្រើនថ្មីៗក្នុងវិស័យកម្មសិទ្ធិឧស្សាហកម្ម ក្នុងនេះ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប(EPO) និងជាមួយបណ្ដាប្រទេសជាដៃគូនានា, ការចូលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (The Patent Cooperation Treaty = PCT) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (The World Intellectual Property Organization =WIPO) និងការចូលជាសមាជិកកិច្ចព្រមព្រៀងទីក្រុងហេច (ឡាអេ) ស្ដីពីការចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ (The Hague Agreement for the International Registration of Industrial Design= Hague Agreement)។ ផ្អែកតាមបទពិសោធន៍ការងារនេះ ខ្ញុំស្នើដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវខិតខំបន្តពង្រឹងការអនុវត្តលើកិច្ចការពារ និងលើកកម្ពស់ការងារកម្មសិទ្ធិឧស្សាហកម្មឱ្យដំណើរការដោយរលូនល្អទៅមុខបន្តទៀត ជាពិសេស ជំរុញការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មទៅវិញទៅមក ជាមួយបណ្ដាប្រទេសនានា។

៤- ត្រូវបន្តយកចិត្តទុកដាក់លើការងារអធិការកិច្ចរោងចក្រ សហគ្រាស ដើម្បីជួយជំរុញ និងពង្រឹងការអនុវត្តច្បាប់, បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេស រាប់ទាំងផ្នែកបច្ចេកទេសឧស្សាហកម្ម និងសុវត្ថិភាពឧស្សាហកម្មផងដែរ។

## គ- ជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

១- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវសហការគ្នាឱ្យកាន់តែល្អ ស្អិតល្មួតជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងវិស័យឯកជន ដើម្បីពង្រឹងយន្តការគាំទ្រ លើការចុះបញ្ជី, ការផ្ដល់សេវាសម្របសម្រួល, ការផ្សព្វផ្សាយព័ត៌មានទីផ្សារឱ្យបានទូលំទូលាយ។

២- ត្រូវបន្តការលើកទឹកចិត្តផលិតកម្មក្នុងស្រុក ដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកជាអាទិភាព និងការបន្តខិតខំស្វែងរកទីផ្សារ ការជួយពង្រឹងសមត្ថភាពប្រកួតប្រជែងដល់ផលិតករ អាជីវករ ដែលជាលទ្ធភាពបង្កឱកាសដល់ផលិតផលខ្មែរយើង ឱ្យកាន់តែឈានមុខក្នុងទីផ្សារ ជំនួសផលិតផលនាំចូលពីខាងក្រៅ, ហើយលើសពីនេះ អាចជ្រៀតចូលទីផ្សារគោលដៅនាំចេញរបស់កម្ពុជាទៀតផង។

៣- ប្រការសំខាន់ចាំបាច់ដែលត្រូវខិតខំសម្រេចឱ្យបានក្នុងឆ្នាំនេះ គឺការរៀបចំ និងដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដើម្បីដាក់ឆ្លងសុំការអនុម័តពីគណៈរដ្ឋមន្ត្រីឱ្យបានឆាប់រហ័ស ក្នុងនោះ ក៏ត្រូវកំណត់អំពីយន្តការដឹកនាំ, សម្របសម្រួលការអនុវត្ត និងសូចនាករសំខាន់ៗជាគន្លឹះ ដែលជះឥទ្ធិពលដល់ការអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម។

## ឃ- ការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត

១- របៀបវារៈអាទិភាពដែលត្រូវយកចិត្តទុកដាក់ខ្ពស់ជាងគេក្នុងវិស័យនេះ គឺការខិតខំអនុវត្តគោលនយោបាយពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាត ដល់គ្រប់ទីកន្លែង ដោយមិនផ្ដោតតែលើទីប្រជុំជននោះទេ។

២- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបន្តឆ្លងយោបល់ឱ្យបានឆាប់ចប់ ជាមួយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំគោលការណ៍រួមអំពីការកំណត់ថ្លៃលក់ទឹក

ស្អាត ដែលក្នុងនោះ នឹងកំណត់ឡើងវិញអំពីថ្លៃលក់ទឹកស្អាតខ្ពស់បំផុត (Ceiling Price) ទៅតាមប្រភេទអ្នកប្រើប្រាស់ តាមតំបន់មានប្រភពទឹក ឬខ្វះប្រភពទឹក និងតាមប្រភេទភូមិសាស្ត្រទីប្រជុំជនខេត្ត ស្រុក ក្រុង ឃុំ សង្កាត់ ដែលមានលក្ខណសម្បត្តិខុសៗគ្នា សំដៅឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានបញ្ជាក់ថា ការកំណត់ថ្លៃលក់ទឹកស្អាតត្រូវផ្អែកលើការគិតគូរច្បាស់លាស់អំពីកត្តាថ្លៃដើមផលិត សំដៅធានាបានទាំងផលប្រយោជន៍អ្នកប្រើប្រាស់ ទាំងផលប្រយោជន៍អ្នកផ្តល់សេវា, ជាពិសេស ជួយសម្រួលដល់ប្រជាជនដែលមានជីវភាពខ្វះខាត់ខ្សោយ។

៣- សហការជាមួយក្រសួងពាក់ព័ន្ធ ខិតខំសម្រេចឱ្យបាននូវសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាត ដើម្បីដាក់ឆ្លងគណៈរដ្ឋមន្ត្រីនៅក្នុងឆ្នាំនេះ។

៤- បន្តអនុវត្តគោលនយោបាយ ដាក់បញ្ចូលវិស័យទឹកស្អាត (ខ្នាតតូច និងមធ្យម) ជាវិស័យអាទិភាពសម្រាប់ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ, ផ្តល់ការលើកលែងពន្ធនាំចូល និង VAT សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច និងមធ្យម ដើម្បីនាំចូលសម្ភារ បរិក្ខា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ។

៥- កសាងឱ្យបានតារាងម៉ាទ្រីស និងផែនទីរួម ដែលអាចពិនិត្យឃើញ និងតាមដានបាននូវស្ថានភាពផ្គត់ផ្គង់ទឹកស្អាតនៅគ្រប់រាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់។ ផ្អែកលើនេះ ត្រូវមានការប្រជុំវាយតម្លៃលើសមត្ថភាពជាក់ស្តែង ដែលអ្នកផ្គត់ផ្គង់ទឹកស្អាតរដ្ឋ និងឯកជន អាចឆ្លើយតប ឬមិនអាចឆ្លើយតបទៅនឹងគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃការផ្គង់ផ្គង់ទឹកស្អាត ១០០% នៅគ្រប់ទីប្រជុំជនត្រឹមឆ្នាំ២០២៥ ដើម្បីមានវិធានការជំរុញចាប់ពីពេលនេះទៅ។

## ខ- ការអភិវឌ្ឍវិស័យស្តង់ដារ

១- ខ្ញុំបានកត់សម្គាល់ឃើញថា ការអនុម័ត និងដាក់ឱ្យប្រើប្រាស់ស្តង់ដារផលិតផល និងប្រព័ន្ធគ្រប់គ្រងមានកំណើនឡើងជាបន្តបន្ទាប់ ដែលគិតដល់ចុងឆ្នាំ២០១៩នេះ យើងសម្រេចបាន ៩២៨ស្តង់ដារ ធៀបនឹងត្រឹមឆ្នាំ២០១៥ មានតែ ៤០៤ស្តង់ដារប៉ុណ្ណោះ។ កត្តានេះ នឹងជួយដល់ការពង្រឹងគុណភាពផលិតផល ពង្រឹងសមត្ថភាពប្រកួតប្រជែង និងបើកផ្លូវឱ្យផលិតផលកម្ពុជាចៀសផុតពីរបាំងបច្ចេកទេស ដើម្បីបញ្ជ្រាបខ្លួនទៅក្នុងទីផ្សារនៃបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។

២- ខ្ញុំសូមស្នើឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏ដូចជាក្រុមប្រឹក្សាស្តង់ដារជាតិ ដែលមានការចូលរួមពីសមាសភាពអន្តរក្រសួងពាក់ព័ន្ធ សូមបន្តធ្វើការសិក្សាស្រាវជ្រាវ, បង្កើត, និងអនុម័តស្តង់ដារផលិតផលឱ្យបានច្រើនថែមទៀត ព្រមទាំងបំផុសស្មារតីផលិតករ អាជីវករ និងអ្នកប្រើប្រាស់ឱ្យចាប់អារម្មណ៍ខ្ពស់លើការតម្រង់ទិសទៅរកស្តង់ដារ គុណភាពផលិតផល ដើម្បីពង្រឹងសុខដុមនីយកម្មក្នុងផលិតកម្ម និងជីវភាពសង្គម។

៣- ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួង និងវិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយនូវរាល់ស្តង់ដារដែលត្រូវបានអនុម័ត។

៤- លើសពីនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ឱ្យស្របនឹងកម្រិតស្តង់ដារអន្តរជាតិ ដើម្បីរួមចំណែកបម្រើឱ្យការធ្វើពិពិធកម្មទីផ្សារផលិតផលកម្ពុជា។

ជាមតិផ្ទាល់របស់ខ្ញុំ ក្រសួងគួរធ្វើការពិចារណា ក្នុងការផ្ទេរសមត្ថកិច្ចអង្គភាពដែលមានលក្ខណៈជាមន្ទីរពិសោធន៍ ឱ្យមកស្ថិតនៅក្រោមវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលគ្រោងនឹងបង្កើតថ្មីនៅពេលខាងមុខ បើសិនជាអាចធ្វើទៅបាន។

**ច- ការងារមាត្រាសាស្ត្រជាតិ**

១- ក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវបន្តពង្រឹងក្របខណ្ឌគតិយុត្តក្នុងវិស័យមាត្រាសាស្ត្រជាតិ ឱ្យបានរឹងមាំបន្ថែមទៀត ដោយដើរទន្ទឹមគ្នានឹងការងារសហប្រតិបត្តិការជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិនានា ដើម្បីធ្វើឱ្យវិស័យមាត្រាសាស្ត្រជាតិដើរតួនាទីកាន់តែឈានមុខ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យឧបករណ៍រង្វាស់រង្វាល់ដែលប្រើប្រាស់ក្នុងការធ្វើពាណិជ្ជកម្ម។

២- អង្គភាពជំនាញ ត្រូវបន្តកិច្ចសហការគ្នាល្អជាមួយស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្កើនការផ្តល់សេវាត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ការធ្វើព្យាសកម្ម តេស្តវិភាគ និងអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ដើរស្របគ្នានឹងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រ។

**ឆ- ការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលរាជរដ្ឋាភិបាលប្រគល់ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មបច្ចុប្បន្ន ជាក្រសួងទទួលបន្ទុកដឹកនាំ គ្រប់គ្រងវិស័យនេះ តាមរយៈការបង្កើតទៅជាក្រសួងថ្មីមួយនៅពេលខាងមុខឆាប់ៗនេះ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

១- ជាមួយនឹងមុខងារ បេសកកម្ម ដូចមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ខ្ញុំស្នើក្រសួងថ្មីនេះ សហការរៀបចំឱ្យបានឆាប់នូវអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ បញ្ហាដែលត្រូវគិតគូរជាអាទិភាព គឺបញ្ហាធនធានមនុស្សដែលមានជំនាញ និងសមត្ថភាពខ្ពស់ត្រូវចូលបម្រើការងារក្នុងវិស័យនេះ ហើយដែលត្រូវរៀបចំបញ្ចូលទៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងថ្មី រួមទាំងកន្លែងធ្វើការ និងមធ្យោបាយបម្រើការងារនៅតាមអង្គភាពថ្មីចំនួនពីរដែលត្រៀមបង្កើតឡើងដោយអនុក្រឹត្យគឺ ***អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍***។

២- ខិតខំដោះស្រាយផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការកែសម្រួលរចនាសម្ព័ន្ធការងារនៅតាមអង្គភាពចំណុះទីស្តីការក្រសួងផង និងនៅតាមមន្ទីររាជធានី ខេត្តផង ដើម្បីស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ និងអនុក្រឹត្យរៀបចំក្រសួងថ្មី។

*ចំណុចខាងលើនេះ យើងនិយាយខ្លី ប៉ុន្តែខ្ញុំយល់ថា កិច្ចការដែលត្រូវធ្វើមានច្រើនស្មុគស្មាញ ដែលត្រូវមានការខិតខំរួមគ្នាដោះស្រាយ និងឆ្លើយតបឱ្យបានសកម្មជាទីបំផុត។*

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងអង្គសន្និបាតទាំងមូល!***

ខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ទោះបីក្រសួងឧស្សាហកម្ម និងសិប្បកម្មទទួលយកនូវការកែទម្រង់រចនាសម្ព័ន្ធដឹកនាំ គ្រប់គ្រងក្នុងរបត់ថ្មីក៏ពិតមែន ប៉ុន្តែក្រោមការដឹកនាំរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** និងសំណុំធន្ទះជាផ្លូងមួយរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទ, ក្រសួងនេះ នឹងនៅតែបំពេញបានល្អតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ហើយឆ្លើយតបបានទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដើម្បី «*កំណើនការងារ សមធម៌ និង ប្រសិទ្ធភាព*» និងអភិវឌ្ឍន៍ជាតិ មាតុភូមិ និងប្រជាជនយើងប្រកបដោយវិបុលភាព និងសុខសន្តិភាព។

មុននឹងបញ្ចប់ ខ្ញុំស្នើដល់គ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងសន្និបាតរយៈពេលបីថ្ងៃនេះ ចូលរួមពិភាក្សា ផ្លាស់ប្តូរយោបល់ ចែករំលែកបទពិសោធន៍ និងចូលរួមវាយតម្លៃលើបញ្ហាប្រឈម ចំណុចខ្សោយ ចំណុចខ្លាំង ដើម្បីផ្តល់ធាតុចូល សម្រាប់ថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏ដូចជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ធ្វើការគិតគូរពិចារណា កែលម្អ និងដាក់ចេញជាវិធានការអនុវត្តក្នុងដំណាក់កាលចំពោះមុខ និងក្នុងរយៈពេលបន្ត។

ខ្ញុំសូមស្នើដល់ក្រសួង ស្ថាប័ន ដៃគូជាតិ អន្តរជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីឱ្យក្រសួងថ្មីនេះ សម្រេចបាននូវការបំពេញបេសកកម្មរបស់ខ្លួន និងបង្កើតបាននូវសមិទ្ធផលថ្មីៗជំនេងថែមទៀត។

ក្នុងឱកាសឆ្នាំថ្មី ឆ្នាំជូត ព.ស.២៥៦៤ ដែលនឹងឈានចូលនៅក្នុងរយៈពេលពីរខែខាងមុខនេះ ខ្ញុំសូមជូនពរ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី**, ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិកាអង្គសន្និបាតទាំងអស់ ជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ *អាយុ វណ្ណៈ សុខៈ ពលៈ* កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យអង្គសន្និបាតទាំងមូល ដំណើរការទៅដោយរលូន នាំមកនូវលទ្ធផលល្អត្រចះត្រចង់ និងសម្រេចបានជោគជ័យ។

តាងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, *ខ្ញុំសូមប្រកាសបើកសន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារ ឆ្នាំ២០២០* ចាប់ពីពេលនេះតទៅ៕

*សូមអរគុណ!*